**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ :១៧៦ អយក.គល.ទន

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសសម្រាប់ឆ្នាំ២០១៧ ថវិកាកម្មវិធីឆ្នាំ២០១៧ ផ្នែកអប់រំ ផ្នែកឧត្តមសិក្សា និងផ្នែកយុវជន និងកីឡា ជំពូក៦០ គណនី៦០០៥ អនុគណនី៦០០៥១ របស់អង្គភាពថវិការដ្ឋបាលកណ្តាល

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសសម្រាប់ឆ្នាំ២០១៧ ថវិកាកម្មវិធីឆ្នាំ២០១៧ ផ្នែកអប់រំ ផ្នែកឧត្តមសិក្សា និងផ្នែកយុវជន និងកីឡា ជំពូក៦០ គណនី៦០០៥ អនុគណនី៦០០៥១ របស់អង្គភាពថវិការដ្ឋបាលកណ្តាល ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក)ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១០ ៨៦៤ / ០២៣ ២២០ ៩២៧ ទូរស័ព្ទ/ទូរសារលេខ៖០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយឯកសារដេញថ្លៃនូវ **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ** ដែលមានទឹកប្រាក់ចំនួន **៧៩ ២០៣ ៤០០រៀល (ចិតសិបប្រាំបួនលាន ពីររយបីពាន់ បួនរយរៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង៣:០០ រសៀល ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើនៅវេលាម៉ោង៣:០០រសៀល ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ